# តើ VCAL គឺជាអ្វីទៅ?

Victorian Certificate of Applied Learning (VCAL) (វិញ្ញាបនបត្ររៀនសូត្រសំរាប់អនុវត្តន៏នៃរដ្ឋវិចតូរីយ៉ា) គឺជាជំរើស ប្រតិបត្តិដោយផ្ទាល់ដៃមួយ សំរាប់សិស្ស Year 11 និង Year 12 ។

VCAL ផ្តល់ឲ្យអ្នកនូវបទពិសោធន៍ទាក់ទងនឹងការងារសំរាប់អនុវត្តន៍ ព្រមទាំងជំនាញការអក្ខរកម្មនិងការចេះគិតលេខ ហើយនិង ឱកាសដើម្បីស្ថាបនាជំនាញការផ្ទាល់ខ្លួន ដែលមានសារសំខាន់សំរាប់ការរស់នៅនិងការប្រកបការងារ។ ហើយដូចគ្នានឹង Victorian Certificate of Education (VCE) (វិញ្ញាបនបត្រសិក្សានៃរដ្ឋវិចតូរីយ៉ា) ដែរនោះ VCAL គឺជាសញ្ញាប័ត្រដែលមានការ ទទួលស្គាល់។

សិស្សដែលរៀនយក VCAL ទំនងជាចាប់អារម្មណ៍ក្នុងការបន្តទៅហ្វឹកហ្វឺននៅឯ TAFE ហាត់រៀនធ្វើការឬទទួលការងារមួយនៅ ក្រោយពីបញ្ចប់ការសិក្សានៅសាលា។ ទោះដូច្នេះក្តី បើអ្នកចាប់ផ្តើម VCAL របស់អ្នក ហើយបន្ទាប់មក សំរេចថា VCE គឺជា ជំរើសត្រឹមត្រូវសំរាប់ខ្លួនអ្នក នោះវានឹងមិនហួសពេលសំរាប់ឲ្យអ្នកផ្លាស់ប្តូរចិត្តនោះឡើយ។ តាមពិតទៅ ផ្នែកនៃមុខវិជ្ជា VCE ណា មួយដែលអ្នកបំពេញជាផ្នែកនៃ VCAL របស់អ្នក នឹងរាប់បញ្ចូលទៅក្នុង VCE របស់អ្នក បើអ្នកសំរេចផ្ទេរប្តូរគ្នារវាងវគ្គសិក្សា ផ្តល់វិញ្ញាបនបត្រទាំងនេះ។

ភាពអាចផ្លាស់ប្តូរបាននៃ VCAL អាចឲ្យអ្នកចាប់យកកម្មវិធីសិក្សាមួយដែលសក្តិសមនឹងផលប្រយោជន៍និងសេចក្តីត្រូវការរៀនសូត្រ របស់អ្នក។ បែបបទនិងផ្នែកនៃមុខវិជ្ជាសិក្សាដែលទទួលស្គាល់ពេញលេញ ត្រូវបានសំរាំងរើសយកឡើងសំរាប់ប្រភេទចាំបាច់ខាន មិនបានចំនួនបួនដូចតទៅនេះ :

- ជំនាញការអក្ខរកម្មនិងចេះគិតលេខ
- ជំនាញការឧស្សាហកម្មជាក់លាក់
- ជំនាញការទាក់ទងនឹងការងារ
- ជំនាញការបណ្តុះបណ្តាលផ្ទាល់ខ្លួន

បើអ្នកបំពេញដោយជោគជ័យនូវ VCAL របស់អ្នក អ្នកនឹងទទួលវិញ្ញាបនបត្រមួយ និងរបាយការណ៍នៃលទ្ធផលដែលផ្តល់ពត៌មាន អំពីមុខវិជ្ជាសិក្សាដែលអ្នកបានបំពេញ។

## អ្វីៗដែលខ្ញុំត្រូវដឹង

### ហេតុអ្វីបានជាខ្ញុំរើសយកការធ្វើ VCAL?

VCE គឺជាជំរើសល្អមួយសំរាប់សិស្សដែលមានបំណងសិក្សាបន្ថែមទៀតនៅឯសាកលវិទ្យាល័យ។ ទោះដូច្នេះក្តី អ្នកប្រហែលជាមាន អារម្មណ៍ថា នេះមិនមែនជាជំរើសត្រឹមត្រូវសំរាប់អ្នកឡើយ។

VCAL គឺជាសញ្ញាប័ត្រមធ្យមសិក្សាជាន់ខ្ពស់ទទួលស្គាល់មួយ ដែលសិក្សានៅ Year 11 និង Year 12 ។

VCAL ត្រូវបានផ្អែកទៅលើការរៀនសូត្រសំរាប់អនុវត្តដោយផ្ទាល់ ដែលត្រូវគេស្គាល់ផងដែរថាជា “ការរៀនសូត្រសំរាប់អនុវត្តន៍”។

បើអ្នកជ្រើសយក VCAL អ្នកនឹងទទួលបទពិសោធន៍ប្រតិបត្តិនិងជំនាញការ“សំរាប់អាចធ្វើការបាន” ព្រមទាំងជំនាញការដែលអ្នកនឹង ត្រូវការដើម្បីទៅហ្វឹកហ្វឺនបន្ថែម នៅក្នុងកន្លែងប្រកបការងារ ឬនៅឯ TAFE ។

## តើខ្ញុំអាចធ្វើ VCAL នៅពេលណា?

អ្នកអាចចាប់ផ្តើមកម្មវិធី VCAL របស់អ្នក នៅ Year 11 ឬ Year 12 នៃសាលាមធ្យមសិក្សា។ VCAL ក៏មាននៅឯវិជ្ជាស្ថាន TAFE ភាគច្រើន និងមជ្ឈមណ្ឌលអប់រំសហគមន៍ជនពេញវ័យ (ACE) មួយចំនួនតូចផងដែរ។

## តើអ្វីទៅដែលជាកំរិតនៃ VCAL?

VCAL មានបីកំរិត - គ្រឹះ មធ្យម និង ជាន់ខ្ពស់។ អ្នកនឹងចាប់ផ្តើមហើយបំពេញ VCAL របស់អ្នក ទៅតាមកំរិតដែលផ្គូរផ្គង នឹងសេចក្តីត្រូវការនិងសមត្ថភាពរបស់អ្នក។

## តើមានតម្រូវការណាមួយសំរាប់ការចូលរៀនឬទេ?

គ្មានទេ។ អ្នកចាប់ផ្តើម VCAL នៅនឹងកំរិតដែលសក្តិសមនឹងសមត្ថភាពរបស់អ្នក។ គ្រូបង្រៀនឬអ្នកប្រឹក្សាយោបល់អាជីពរបស់អ្នក នឹងអាចជួយអ្នកក្នុងការសំរេចនូវកំរិតមួយណាដែលសក្តិសមសំរាប់អ្នក។

## តើខ្ញុំនឹងត្រូវការរយៈពេលប៉ុន្មាន ដើម្បីបញ្ចប់ VCAL?

VCAL បានត្រូវបង្កើតឡើងសំរាប់សិស្ស Year 11 និង Year 12 ។ អ្នកអាចទទួលវិញ្ញាបនបត្រ VCAL និងរបាយការណ៍លទ្ធផល នៅពេលដែលអ្នកបំពេញដោយជោគជ័យនូវកម្មវិធី VCAL របស់អ្នក សំរាប់កំរិតដែលអ្នកបានជ្រើសយក។

## តើអ្នកនឹងទទួលបានអ្វីទៅនៅក្រោយពីបំពេញ VCAL ដោយជោគជ័យ?

បើអ្នកបំពេញកម្មវិធី VCAL របស់អ្នកដោយជោគជ័យ អ្នកនឹងទទួលវិញ្ញាបនបត្រ VCAL សំរាប់កំរិតគ្រឹះ មធ្យម ឬ ជាន់ខ្ពស់ ដោយអាស្រ័យលើកំរិត VCAL ដែលអ្នកជ្រើសយកដើម្បីសិក្សា។ អ្នកក៏នឹងទទួលរបាយការណ៍លទ្ធផលមួយផងដែរ ដែលរាយ ផ្នែកនៃមុខវិជ្ជាទាំងអស់របស់ VCAL, VCE និង VCE VET។

## តើខ្ញុំអាចសិក្សា VCAL នៅទីណា?

សាលា វិជ្ជាស្ថាន TAFE និងមជ្ឈមណ្ឌលអប់រំសហគមន៍ជនពេញវ័យ (ACE) ខ្លះ កំពុងផ្តល់ VCAL ។ សូមបើកមើលវិបសៃ www.vqa.gov.au ដើម្បីមើលឈ្មោះស្ថាប័នទាំងឡាយដែលផ្តល់ VCAL ។

## តើអ្វីទៅដែលរាប់បញ្ចូលទៅក្នុង VCAL របស់ខ្ញុំ?

## តើវិញ្ញាបនបត្រសិក្សានិងហ្វឹកហ្វឺនវិជ្ជាជីវៈ (VET) គឺជាអ្វីទៅ?

កម្មវិធីហ្វឹកហ្វឺន VET ផ្តល់ឱកាសមួយសំរាប់សាលា ស្ថាប័នហ្វឹកហ្វឺន និង ឧស្សាហកម្ម ដើម្បីធ្វើការរួមគ្នា ក្នុងការរៀបចំសិស្ស សំរាប់ការប្រកបការងារនិងហ្វឹកហ្វឺនបន្ថែមទៀត។ សាលាមធ្យមសិក្សាភាគច្រើន ផ្តល់វគ្គសិក្សានិងហ្វឹកហ្វឺនវិជ្ជាជីវៈ (VET) ដែលរួម ចំណែកឯលការបំពេញគួរជាទីពេញចិត្តនៃតម្រូវការរបស់ VCAL ហើយផ្តល់លក្ខណៈសម្បត្តិសិក្សាអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈ មួយដែលទទួលស្គាល់ទូទាំងប្រទេស។

## តើវិញ្ញាបនបត្រនេះនឹងត្រូវបានរាប់បញ្ចូលទៅក្នុង VCAL របស់ខ្ញុំដែរឬទេ?

ត្រូវហើយ ការសិក្សានេះនឹងអាចរាប់បញ្ចូលបាន។ អ្នកគួរពិភាក្សាជាមួយគ្រូបង្រៀនឬអ្នកប្រឹក្សាយោបល់អាជីពរបស់អ្នក ដើម្បីគិត រកមើលការសិក្សាអ្វីទៅដែលអ្នកបានរៀនកាលពីគ្រាមុន ហើយអាចរាប់បញ្ចូលទៅក្នុង VCAL របស់អ្នក ហើយដើម្បីគ្រោងសិក្សា មុខវិជ្ជាសេសសល់នៃកម្មវិធី VCAL របស់អ្នក។

## ខ្ញុំបានសិក្សាមុខវិជ្ជាមួយរបស់ VCE រួចហើយ។ តើមុខវិជ្ជានេះនឹងត្រូវបានរាប់បញ្ចូលទៅក្នុង VCAL របស់ខ្ញុំដែរឬទេ?

បើអ្នកទទួលលទ្ធផល ‘S’ សំរាប់ការបំពេញគួរជាទីពេញចិត្តនូវផ្នែកនៃមុខវិជ្ជារបស់ VCE ណាមួយនោះ ផ្នែកនៃមុខវិជ្ជានេះនឹងត្រូវ បានរាប់បញ្ចូលទៅក្នុង VCAL របស់អ្នក។ អ្នកគួរពិភាក្សាជាមួយគ្រូបង្រៀន ឬអ្នកប្រឹក្សាយោបល់អាជីពរបស់អ្នក ដើម្បីគ្រោង សិក្សាមុខវិជ្ជាសេសសល់នៃកម្មវិធី VCAL របស់អ្នក។

## បើខ្ញុំកែប្រែចិត្ត តើខ្ញុំអាចផ្លាស់ទៅ VCE បានឬទេ?

អាចផ្លាស់បាន។ បើអ្នកកែប្រែចិត្ត ហើយចង់ផ្លាស់ទៅកាន់ VCE ឬបើអ្នកចង់សិក្សា VCE តទៅទៀត ក្រោយពីបញ្ចប់ VCAL ហើយនោះ ផ្នែកនៃមុខវិជ្ជា VCE ណាមួយដែលបានបញ្ចប់ដោយជោគជ័យ ជាផ្នែកនៃ VCAL របស់អ្នក នឹងត្រូវរាប់បញ្ចូល ទៅក្នុង VCE របស់អ្នក។
អ្នកក៏ប្រហែលជាអាចផ្ទេរឥណទានសំរាប់ផ្នែកនៃមុខវិជ្ជាឬបែបបទទាំងពួងដែលបានបញ្ចប់ជាផ្នែកនៃ VCAL របស់អ្នកផងដែរ។ អ្នកគួរពិភាក្សាជាមួយគ្រូបង្រៀនឬអ្នកប្រឹក្សាយោបល់អាជីពរបស់អ្នក បើអ្នកសំរេចរើសយកជំរើសនេះ។

## តើខ្ញុំអាចធ្វើការមិនពេញពេល និង/ឬបន្តការហាត់រៀនធ្វើការ នៅក្នុងពេលចុះឈ្មោះនៅក្នុង VCAL ដែរឬទេ?

អ្នកអាចទទួលការទទួលស្គាល់និងឥណទានចំពោះការងារមិនពេញពេល នៅក្នុងពេលចុះឈ្មោះនៅក្នុង VCAL ។ ការងារនេះ អាចរួមមាន :

- ការហាត់រៀនធ្វើការ ឬ ការបណ្តុះបណ្តាលការងារមិនពេញពេល
- ការងារមិនពេញពេល
- ការដាក់នៅកន្លែងធ្វើការដើម្បីឲ្យមានបទពិសោធន៍ការងារ។

## តើ VCAL ត្រូវបានពិនិត្យវាយតម្លៃតាមរបៀបណា?

VCAL គឺជាការគួបផ្សំនៃវគ្គសិក្សា / វិញ្ញាបនបត្រដែលទទួលស្គាល់ទាំងអស់។ ផ្នែកនីមួយៗនៃកម្មវិធីរបស់អ្នក ត្រូវបានពិនិត្យវាយ តម្លៃដោយយោងទៅតាមតម្រូវការពិនិត្យវាយតម្លៃសំរាប់ផ្នែកនីមួយៗនៃកម្មវិធី។

## តើខ្ញុំត្រូវធ្វើ General Achievement Test (GAT) (តេស្តលទ្ធផលទូទៅ)ឬទេ?

GAT គឺជាតេស្តអំពីតិរិះវិជ្ជានិងជំនាញការក្នុងការសរសេរ, គណិតសាស្ត្រ, វិទ្យាសាស្ត្រនិងបច្ចេកវិជ្ជា, មនុស្សជាតិនិងវិទ្យាសាស្ត្រ សង្គម ហើយនិងសិល្បៈ។ តេស្តនេះត្រូវធ្វើដោយសិស្ស VCE ទាំងអស់ ដែលរៀនលំដាប់របស់ផ្នែកនៃមុខវិជ្ជាទី 3 និងទី 4 របស់ VCE ។ ចាប់ពីឆ្នាំ 2007 តទៅ សិស្សដែលសិក្សាលំដាប់ផ្នែកទី 3-4 នៃ VCE VET ដែលទទួលពិន្ទុ

ក៏នឹងត្រូវតែប្រឡង GAT ដែរ។ យ៉ាងណាមិញ អ្នកអាចរើសយកការប្រឡង GAT បើវាសមរម្យនឹងផ្លូវដើររបស់អ្នកទៅកាន់ការសិក្សាអប់រំ ហ្វឹកហ្វឺនបន្ថែម ឬការប្រកបការងារ។

## តើខ្ញុំសិក្សាអំពីអ្វីទៅ?

ដោយមានជំនួយពីគ្រូបង្រៀនឬអ្នកប្រឹក្សាយោបល់អាជីពរបស់អ្នក អ្នកអាចបង្កើតកម្មវិធី VCAL មួយដែលសមស្របនឹងសេចក្តី ត្រូវការរៀនសូត្រនិងការចាប់អារម្មណ៍ជាក់លាក់របស់អ្នក។ អ្នកមានជំរើសក្នុងការរើសយកផ្នែកនៃមុខវិជ្ជានិងបែបបទទាំងពួង សំរាប់ ប្រភេទណាមួយក្នុងចំណោមប្រភេទ VCAL បួនដែលចាំបាច់ខានមិនបាន :

## ប្រភេទទី 1 - ជំនាញការអក្ខរកម្មនិងការចេះគិតលេខ

កម្មវិធី VCAL របស់អ្នក ត្រូវរួមបញ្ចូលទាំងមុខវិជ្ជាអក្ខរកម្មនិងការចេះគិតលេខ។ អ្នកអាចរើសយកមុខវិជ្ជាទាំងនេះចេញពីបណ្តា ផ្នែកនៃមុខវិជ្ជាជំនាញការអក្ខរកម្ម VCAL និងជំនាញការចេះគិតលេខ VCAL ហើយនិងគណិតសាស្ត្រនិងអង់គ្លេស VCE ឬ មុខវិជ្ជាសិក្សាអប់រំបន្តឯទៀត ដូចជា Certificate in General Education (វិញ្ញាបនបត្រសិក្សាទូទៅ) (ជនពេញវ័យ) ដែលជា វគ្គសិក្សាមួយផ្តល់ឲ្យតាមរយៈវិជ្ជាស្ថាន TAFE និងមជ្ឈមណ្ឌល ACE ដែលបង្កើតជំនាញការអក្ខរកម្មនិងចេះគិតលេខ ហើយមាន សារសំខាន់សំរាប់ផ្លូវដើរទៅកាន់ការប្រកបការងារនិងវិជ្ជាជីវៈ។

## ប្រភេទទី 2 - ជំនាញការជាក់លាក់សំរាប់ឧស្សាហម្ម

កម្មវិធី VCAL របស់អ្នក ត្រូវរួមបញ្ចូលផ្នែកនៃមុខវិជ្ជាជាក់លាក់សំរាប់ឧស្សាហកម្ម ចេញពីកម្មវិធីសិក្សានិងហ្វឹកហ្វឺនវិជ្ជាជីវៈ (VET) ឬ VCE VET (វិញ្ញាបនបត្រវិជ្ជាជីវៈដែលត្រូវបានទទួលស្គាល់ទូទាំងប្រទេស ដែលរួមបញ្ចូលក្នុងវង្វង់ VCE)។ យ៉ាងណាមិញ គេមិនតម្រូវឲ្យអ្នកផ្តោតទៅលើ ឬបំពេញវិញ្ញាបនបត្រតែមួយគត់ណាមួយរបស់ VET ឡើយ។ ឧទាហរណ៍: អ្នកអាចរើសយក បែបបទឬផ្នែកនៃមុខវិជ្ជាផ្សេងៗគ្នាចេញពីវិញ្ញាបនបត្រ VET មួយចំនួន ដើម្បីបំពេញតាមតម្រូវការនៃ VCAL ហើយទទួលបទ ពិសោធន៍ក្នុងផ្នែកវិជ្ជាជីវៈផ្សេងៗ។ ជំរើស VET មានសភាពធំទូលាយ ហើយមានរួមទាំងយានយន្ត, វិស្វកម្ម, អគារនិងសំណង់, ការទទួលស្វាគមន៍និងលក់រាយ, ពហុពត៌មាន, IT, កសិកម្ម, សាកវប្បកម្ម, ឃ្លាំងស្តុកទំនិញ ហើយនិងសក់ និង សោភ័ណភាព។

## ប្រភេទទី 3 - ជំនាញការទាក់ទងនឹងការងារ

ដើម្បីបង្កើតជំនាញការ“ធ្វើការបាន” VCAL ផ្តល់ឲ្យអ្នកនូវជំរើសក្នុងការដាក់នៅកន្លែងធ្វើការដែលរៀបចំសំរាប់ឲ្យមានបទពិសោធន៍ ការងារ ឬ ការហាត់រៀនធ្វើការ / បណ្តុះបណ្តាលមិនពេញពេល, ការងារមិនពេញពេល ឬ បទពិសោធន៍ការងារ។ អ្នកក៏អាចរៀនផ្នែកនៃមុខវិជ្ជានិងបែបបទនានាដែលនឹងជួយរៀបចំអ្នកសំរាប់ធ្វើការផងដែរ ឧទាហរណ៍: ជំនាញការសុវត្ថិភាពនិងសុខភាពកន្លែងការងារ (OH&S) ឬ សំភាសន៍ធ្វើការ។

## ប្រភេទទី 4 - ជំនាញការរីកចំរើនផ្ទាល់ខ្លួន

ជាផ្នែកនៃកម្មវិធី VCAL របស់អ្នក អ្នកនឹងចូលរួមក្នុងគំរោងការងារនិងសកម្មភាពទាំងពួង នៅក្នុងសហគមន៍ឬសាលាអ្នក ដែលនឹង ជួយអ្នកក្នុងការបង្កើតជំនាញការនៃកិច្ចការជាក្រុម ការជឿជាក់លើខ្លួនឯង និងជំនាញការឯទៀត ដែលសំខាន់សំរាប់ការរស់នៅនិង ការធ្វើការងារ។ ឧទាហរណ៍:

សាលាអ្នកអាចធ្វើការជាមួយសាលាក្រុងដើម្បីកែលំអសួនឧទ្យាន។ ការរៀនសូត្រដែលអ្នកទទួលក្នុងការធ្វើគំរោងការងារនិងសកម្មភាពនេះ អាចរាប់បញ្ចូលទៅក្នុង VCAL របស់អ្នក។

# តើ VCAL អាចយកខ្ញុំទៅកាន់ទីណា?

## តើខ្ញុំអាចចូលទៅសិក្សាថ្នាក់ខ្ពស់ទៀតឬទេ បើខ្ញុំបញ្ចប់ VCAL ដោយជោគជ័យ?

បើអ្នកកំពុងពិចារណាលើការចូលទៅរៀននៅសាកលវិទ្យាល័យនៅពេលចេញពីសាលាភ្លាមនោះ VCAL ប្រហែលជាមិនមែនជំរើស ល្អបំផុតសំរាប់អ្នកឡើយ។ ជាធម្មតា សិស្សដែលគ្រោងចូលសិក្សាថ្នាក់ខ្ពស់ថែមទៀត ធ្វើ VCE ដែលអនុញ្ញាតឲ្យគេទទួលពិន្ទុ ENTER ពី VTAC ។ បើអ្នកកំពុងសិក្សា VCAL នៅនឹងកំរិតជាន់ខ្ពស់ ហើយសំរេចថា អ្នកប្រហែលជាចាប់អារម្មណ៍ក្នុងការ ទៅសិក្សានៅសាកលវិទ្យាល័យ អ្នកគួរពិភាក្សាជាមួយគ្រូបង្រៀនឬអ្នកប្រឹក្សាយោបល់អាជីពរបស់អ្នក ដោយសារតែសាកលវិទ្យាល័យខ្លះនឹងពិចារណាទទួលយកសិស្សដែលមានវិញ្ញាបនបត្រជាន់ខ្ពស់ VCAL ។ យ៉ាងណាមិញ ការចេញពីសាលាចូលទៅសិក្សានៅសាកលវិទ្យាល័យតែម្តងនោះ មិនមែនជាផ្លូវ VET មួយគត់ដើម្បីចូលនោះឡើយ។ អ្នកខ្លះសិក្សាវគ្គអប់រំនិងហ្វឹកហ្វឺនវិជ្ជាជីវៈនៅ TAFE ដោយប្រហែលជាសិក្សាយកសញ្ញាប័ត្រឌីប្លូម៉ា ឬ ឌីប្លូម៉ាជាន់ខ្ពស់ បន្ទាប់មកសំរេចថា គេនឹងទទួលប្រយោជន៍ចេញពីវគ្គសិក្សានៅសាកលវិទ្យាល័យ។ VCAL នឹងជាការចាប់ផ្តើមដ៏ល្អមួយ នៅតាមផ្លូវដើរនេះ។

## តើខ្ញុំមានជំរើសអ្វីទៅ នៅពេលដែលខ្ញុំបានបញ្ចប់ VCAL ហើយ?

VCAL នឹងផ្តល់ឲ្យអ្នកនូវបទពិសោធន៍ទាក់ទងនឹងការងារសំរាប់អនុវត្តន៍ និងសញ្ញាប័ត្រមួយដែលនឹងទទួលស្គាល់ដោយវិជ្ជាស្ថាន TAFE និងនិយោជក។ ទាំងអស់នេះ នឹងជួយអ្នកឲ្យចេញពីសាលាទៅកាន់ការប្រកបការងារ ការហាត់រៀនធ្វើការឬបណ្តុះបណ្តាល និង / ឬ ការហ្វឹកហ្វឺនបន្ថែមនៅ TAFE ។

ជាជំរើសផ្សេងពីនេះ បើអ្នកចាប់ផ្តើមការសិក្សាសំរាប់ VCAL របស់អ្នកនៅនឹងកំរិតគ្រឹះ នៅក្នុង Year 11 ហើយបានបញ្ចប់វាដោយ ជោគជ័យ អ្នកអាចពិចារណាលើការបន្តទៅបំពេញកំរិតមធ្យមឬជាន់ខ្ពស់របស់ VCAL នៅក្នុង Year 12 ។ ឬមួយអ្នកប្រហែល ជាពិចារណានូវជំរើសទាំងពួងរបស់អ្នក ហើយសំរេចថា ផ្ទុយទៅនឹងអ្វីដែលបានគិតទុក អ្នកយល់ថា សាកលវិទ្យាល័យគឺជាជំរើស ត្រឹមត្រូវចំពោះអ្នក ដូច្នេះអ្នកក៏ផ្ទេរទៅសិក្សា VCE វិញ។

## តើ VCAL នឹងធ្វើឲ្យខ្ញុំត្រៀមលក្ខណៈជាស្រេចដើម្បីចូលទៅក្នុងការប្រកបអាជីវកម្មឬទេ?

នៅពេលដែលអ្នកបានបញ្ចប់ VCAL របស់អ្នកហើយ អ្នកនឹងបានទទួលឥណទានសំរាប់វិញ្ញាបនបត្រអាជីវកម្មនិងឧស្សាហកម្មមួយ ហើយនឹងមានតំរិះវិជ្ជាក្នុងផ្នែកទាំងឡាយ ដូចជា Occupational Health & Safety (OH&S) (សុវត្ថិភាពនិងសុខភាពកន្លែង ការងារ) ជាដើម។ ការរៀនសូត្រជាមុននេះនឹងត្រូវបានទទួលស្គាល់ និងរាប់បញ្ចូលទៅក្នុងការហាត់រៀនធ្វើការនិងការបណ្តុះបណ្តាល របស់អ្នក។

ដើម្បីទទួលព័ត៌មានបន្ថែមអំពី VCAL សូមទាក់ទង Victorian Curriculum and Assessment Authority តាមទូរស័ព្ទ លេខ 1800 134 197 ឬបើកវ៉ិបសៃ www.vcaa.vic.edu.au